**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល**

លេខ..២២.០៨...០១.គសឌ..ឈសក.

# លិខិតបង្គាប់ការ
# ស្ដីពី
# ការបែងចែកភារកិច្ចជូនអគ្គលេខាធិការ និង អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល

## អគ្គលេខាធិការ
## នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល
- បានឃើញប្រកាសលេខ ២៦៩ សហវ.ប្រក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល
- យោងតាមតម្រូវការចាំបាច់នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល

## សម្រេច

**ប្រការ ១**.-

កំណត់បែងចែងភារកិច្ច និង ការទទួលខុសត្រូវរបស់អគ្គលេខាធិការ និង អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ក្នុងគោលដៅធានាប្រសិទ្ធភាព និងគណនេយ្យភាពក្នុងការដឹកនាំអនុវត្ត និង បំពេញតួនាទីភារកិច្ចប្រចាំថ្ងៃរបស់ថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល។

**ប្រការ ២**.-

អគ្គលេខាធិការ និង អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ត្រូវបែងចែងភារកិច្ច និង ការទទួលខុសត្រូវ ដូចខាងក្រោម៖

១. ខ្ញុំ **គង់ ម៉ារី** ទទួលបន្ទុកការងាររួម និង ទទួលបន្ទុកដឹកនាំគ្រប់គ្រង ពិនិត្យ និង ផ្ដល់យោបល់លើការអនុវត្តកិច្ចការងារ របស់នាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ និង ធនធានមនុស្ស។

២. ឯកឧត្តមបណ្ឌិត **ឈៀង វណ្ណមុនិណ្ណ** អគ្គលេខាធិការរង, ជាសេនាធិការឱ្យអគ្គលេខាធិការ ទទួលបន្ទុកដឹកនាំគ្រប់គ្រង ពិនិត្យ និង ផ្តល់យោបល់លើការអនុវត្តកិច្ចការងារ និង រាល់ឯកសាររដ្ឋបាលនានា របស់នាយកដ្ឋានបណ្តុះបណ្តាល ផ្សព្វផ្សាយ និង សហប្រតិបត្តិការ និង នាយកដ្ឋានតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ។

៣. ឯកឧត្តមបណ្ឌិត **តាំង ខុនលី** អគ្គលេខាធិការរង, ជាសេនាធិការឱ្យអគ្គលេខាធិការ ទទួលបន្ទុកដឹកនាំគ្រប់គ្រង ពិនិត្យ និង ផ្តល់យោបល់លើការអនុវត្តកិច្ចការងារ និង រាល់ឯកសាររដ្ឋបាលនានា របស់នាយកដ្ឋានស្រាវជ្រាវ គោលនយោបាយ និង ច្បាប់ និង នាយកដ្ឋានគម្រោងនវានុវត្តន៍ និង កម្មវិធីអភិវឌ្ឍ និង គោលការណ៍ណែនាំវាយតម្លៃគម្រោង។

**ប្រការ ៣.-**

ក្រៅពីភារកិច្ច និង ទំនួលខុសត្រូវដូចបានកំណត់ក្នុងប្រការ ២ ខាងលើ, អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវទទួលបន្ទុកអនុវត្តកិច្ចការងារដោយឡែកផ្សេងទៀត តាមការចាត់តាំង និង ការប្រគល់ភារកិច្ចរបស់អគ្គលេខាធិការ ស្របតាមការចាំបាច់ និងតម្រូវការការងារជាក់ស្តែងរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល។

ក្នុងករណីអគ្គលេខាធិការរងទទួលបន្ទុកជាប់បំពេញបេសកកម្ម ឬបន្តការសិក្សានៅក្រៅប្រទេស ឬអវត្តមានរយៈពេលវែង, នាយកដ្ឋានក្រោមឱវាទត្រូវដាក់ឆ្លងកិច្ចការងារ ឬឯកសារនានារបស់នាយកដ្ឋានមកថ្នាក់ដឹកនាំ ដែលទទួលបានការប្រគល់សិទ្ធិជំនួស ឬអាចដាក់ជូនមកអគ្គលេខាធិការ ប្រសិនជាមិនមានការប្រគល់សិទ្ធិជំនួសនោះទេ។

**ប្រការ ៤.-**

លិខិតបទដ្ឋាន និងការសម្រេចទាំងឡាយណាដែលផ្ទុយនឹងលិខិតបង្គាប់ការនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គលេខាធិការរង និង គ្រប់ប្រធាននាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ត្រូវអនុវត្តលិខិតបង្គាប់ការនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ១១រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ សីហា ឆ្នាំ២០២២

**អគ្គលេខាធិការ**

**នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល**

បណ្ឌិត **គង់ ម៉ារី**

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ**

**នៃលិខិតបង្គាប់ការ** ២២០៨-០០១ គសធឧ.សបក **ចុះថ្ងៃទី** ២៣ **ខែ** មីនា **ឆ្នាំ** ២០២២

**ស្តីពីការបែងចែកភារកិច្ចជូនអគ្គលេខាធិការ និង អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល** (គ.ស.ធ.ឌ.)

## តារាងបែងចែកភារកិច្ចថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ.

- **បណ្ឌិត គង់ ម៉ារី** — អគ្គលេខាធិការ
  - នាយកដ្ឋាន រដ្ឋបាល ហិរញ្ញវត្ថុ និងធនធានមនុស្ស
    - ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
    - ការិយាល័យធនធានមនុស្ស
  - **បណ្ឌិត តាំង ងួនលី** — អគ្គលេខាធិការរង
    - នាយកដ្ឋាន ស្រាវជ្រាវ គោលនយោបាយ និងច្បាប់
      - ការិយាល័យស្រាវជ្រាវ
      - ការិយាល័យគោលនយោបាយ និងច្បាប់
    - នាយកដ្ឋាន គម្រោង នវានុវត្តន៍ និង កម្មវិធីអភិវឌ្ឍ
      - ការិយាល័យគម្រោង និងកម្មវិធីអភិវឌ្ឍ
      - ការិយាល័យនវានុវត្តន៍
  - **បណ្ឌិត ឈៀង វណ្ណមុនិណ្ណ** — អគ្គលេខាធិការរង
    - នាយកដ្ឋាន បណ្តុះបណ្តាល ផ្សព្វផ្សាយ និងសហប្រតិបត្តិការ
      - ការិយាល័យបណ្តុះបណ្តាល
      - ការិយាល័យផ្សព្វផ្សាយ និងសហប្រតិបត្តិការ
    - នាយកដ្ឋាន តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
      - ការិយាល័យតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
      - ការិយាល័យផែនការ សរុប និងស្ថិតិ